# ការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី
# ផ្នែក 3
# ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្ដីសម្រេចបញ្ជាប់
# នៃការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី
# សេចក្ដីពន្យល់បន្ថែម

ថ្ងៃទី25 ខែមេសា ឆ្នាំ2018

ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់
MAEDA Yuta

- Slide 3

នៅប្រទេសជប៉ុន ចំពោះដីកាសម្រេចរក្សាការពារដែលមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ គឺគ្រាន់តែសរសេរនូវខ្លឹមសារនៃសំអាងហេតុនឹងមានភាពគ្រប់គ្រាន់ ហេតុនេះ ក្នុងករណីដែលជាដីកាសម្រេចទទួលស្គាល់នូវការរឹបអូសជាបណ្តោះអាសន្ន ឬ ចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ហើយដោយធ្វើការពិចារណាអំពីភាពធាប់រហ័ស នោះគេនឹងសរសេរសំអាងហេតុជាលក្ខណៈកំណត់ថា "ទទួលស្គាល់ថា ពាក្យសុំរបស់ម្ចាស់បំណុលមានភាពត្រឹមត្រូវ" ។

នៅប្រទេសជប៉ុន នៅមុនពេលចេញដីកាសម្រេចគេក៏បង្គាប់ឲ្យដាក់ប្រាតិភោគក្នុងពេលតែមួយផងដែរ ហេតុនេះគេក៏សរសេរអំពីប្រាតិភោគនៅក្នុងលិខិតដីកាសម្រេចដែរ។

- Slide 4

ផ្នែកដែលស្តីអំពី "សិទ្ធិលើបំណុលខាងលើដែលម្ចាស់បំណុលមានចំពោះកូនបំណុល" គឺជាផ្នែកដែលកំណត់អំពីសិទ្ធិដែលត្រូវរក្សាការពារ។ មូលហេតុដែលចាំបាច់ត្រូវកំណត់ ព្រោះ ជាការជូនដំណឹងអំពីមូលហេតុនៃការរឹបអូសជាបណ្តោះអាសន្នទៅកាន់កូនបំណុល ហើយផ្តល់ឱកាសឲ្យកូនបំណុលអាចមានវិវាទ និង មានភាពចាំបាច់ឲ្យមានការសម្រេចសេចក្តីដែលមានភាពដូចគ្នា នៅពេលដែលផ្ទេរទៅការអនុវត្តដាក់ស្តែង ឬ ការបង្គាប់ឲ្យដាក់ពាក្យបណ្តឹងអង្គសេចក្តីជាដើម។

ផ្នែកដែលស្តីអំពី "ដើម្បីរក្សាការពារនូវការអនុវត្ត" បង្ហាញថា សិទ្ធិលើបំណុលដែលធ្វើការទាមទារគឺជា "សិទ្ធិដែលត្រូវរក្សាការពារ" ។

ផ្នែកដែលស្តីអំពី "ជាកម្មសិទ្ធិកូនបំណុល" ជាផ្នែកដែលបង្ហាញថា តុលាការបានទទួលស្គាល់ថា កម្មវត្ថុគឺស្ថិតនៅក្រោមកម្មសិទ្ធិរបស់កូនបំណុល។ ដោយសារតែក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៣១ ចំណុច ក ការរឹបអូសជាបណ្តោះ ជា "ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យរបស់កូនបំណុលដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំនៃសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យបង់ជាប្រាក់" ហេតុនេះ កម្មវត្ថុចាំបាច់ត្រូវតែជាទ្រព្យសម្បត្តិរបស់កូនបំណុល។

ផ្នែកដែលស្តីអំពី "អចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុ..............." គឺជាការកំណត់អំពីអចលនវត្ថុដែលជាកម្មវត្ថុ។

ផ្នែកដែលស្តីអំពី "រឹបអូសជាបណ្តោះអាសន្ន" បង្ហាញអំពីប្រភេទនៃដីកាសម្រេចរក្សាការពារ។

ផ្នែកដែលស្តីអំពី "កូនបំណុលអាចទាមទារឲ្យលុបចោលនូវការចាត់ចែងការអនុវត្តនៃដីកាសម្រេចនេះបាន នៅពេលដែលបានផ្ញើប្រាក់ចំនួន...........ដុល្លារ" គឺជាការកំណត់អំពី ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៤៧ កថា.ទី១) ហើយជាចំណុចដែលចាំបាច់ក្នុងការសរសេរ។

យ៉ាងណាមិញ នៅប្រទេសជប៉ុន នៅក្នុងដីកាសម្រេចទទួលស្គាល់នូវការរក្សាការពារមិនបានសរសេរអំពីបន្ទុកនៃសោហ៊ុយនីតិវិធីទេ។ មូលហេតុ គឺ ការធ្វើឧបាស្រ័យចំពោះដីកាសម្រេចទទួល

ស្គាល់នូវការរក្សាការពារ គឺជាការតវ៉ាអំពីការរក្សាការពារទៅតុលាការនៃការជំនុំជម្រះលើកទី១ ដដែល ហេតុនេះហើយ គេគិតថា ដីកាសម្រេចទទួលស្គាល់នូវការរក្សាការពារ មិនមែនជាការសម្រេចសេចក្តីបញ្ចប់រឿងក្តីទេ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៦៥ កថា.ទី១)។

- Slide 5

នៅប្រទេសជប៉ុន សេចក្តីសម្រេចបញ្ចប់គេបញ្ចូលខ្លឹមសារថា "កូនបំណុលទី៣ មិនត្រូវបង់កាតព្វកិច្ចដែលទាក់ទងនឹងការរឹបអូសជាបណ្តោះអាសន្នទៅឲ្យកូនបំណុលបានទេ"។ នេះគឺជា ដីកាសម្រេចអំពីការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៦៦ កថា.ទី១)។ នៅប្រទេសជប៉ុន ចំពោះរឿងក្តីនៃការរឹបអូសជាបណ្តោះអាសន្ននូវសិទ្ធលើបំណុលបែបនេះ ត្រូវបានបកស្រាយថា ស្របពេលជាមួយគ្នានៃការដាក់ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ វាក៏ជាពាក្យសុំអនុវត្តនូវការរក្សាការពារដែលមានលក្ខខណ្ឌបង្កង់ក្នុងការចេញដីកាសម្រេចរក្សាការពារផងដែរ ហេតុនេះហើយ ទើបគេលើកឡើងនូវដីកាសម្រេចអំពីការអនុវត្តក្នុងដំណាក់កាលនេះ។

ហើយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននូវសិទ្ធិលើបំណុល នឹងត្រូវបានអនុវត្តតាមរយៈការបញ្ជូនទៅកាន់កូនបំណុលទី៣។

នៅប្រទេសកម្ពុជាក៏អនុញ្ញាតឲ្យធ្វើការពិចារណាលើការអនុវត្តនាពេលអនាគត ហើយសរសេរពាក្យពេចន៍បែបនេះនៅក្នុងសេចក្តីសម្រេចចុងក្រោយដែរ។ ប៉ុន្តែ ទោះបីជាមានពាក្យពេចន៍បែបនេះក៏ដោយ មិនអាចអនុវត្តបានទេបើសិនជាគ្មានពាក្យសុំ។

- Slide 6

ដោយសារតែដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ អាចចេញបានដោយមិនចាំបាច់កំណត់កម្មវត្ថុ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៤៦ វាក្យខណ្ឌទី២) ហេតុនេះ ចាំបាច់ធ្វើការកំណត់កម្មវត្ថុតាមវិធីណាមួយ។ ការរឹបអូសជាបណ្តោះអាសន្ន គឺជាប្រព័ន្ធដែលធ្វើការធានានូវតម្លៃទ្រព្យដែលស្មើនឹងតម្លៃសិទ្ធិលើបំណុលដែលទាមទារ ហេតុនេះ ចាំបាច់សរសេរ អំពីកម្មវត្ថុក្នុងកម្រិតមួយដែលអាចធានាបាន នូវតម្លៃនៃទ្រព្យសម្បត្តិដែលស្មើនឹងតម្លៃសិទ្ធិលើបំណុលដែលទាមទារ។ ការសរសេរថា "ស្មើនឹងចំនួនសិទ្ធិលើបំណុលដែលទាមទារខាងលើ" នៅក្នុងសេចក្តីសម្រេចចុងក្រោយ គឺជាការសរសេរអំពីគោលបំណងបែបនោះ។

បើសិនមិនមែនជាទ្រព្យដែលត្រូវផ្លាក់លើកូនបំណុលទេ នៅពេលអនុវត្តដោយបង្ខំជាក់ស្តែង នឹងមិនអាចរឹបអូសបានទេ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៧៩) ឧទាហរណ៍ដូចជា ការរឹបអូសដែលសរសេរថា "ចលនវត្ថុដែលជាកម្មសិទ្ធិរបស់បុគ្គលផ្សេងក្រៅពីកូនបំណុល ដែលកូនបំណុលកំពុងកាន់កាប់" តុលាការនឹងមិនទទួលស្គាល់ខ្លឹមសារបែបនេះទេ ហេតុនេះហើយ ទើបនៅក្នុងសេចក្តីសម្រេចបញ្ចប់បានសរសេរថា "ចលនវត្ថុដែលកូនបំណុលមានកម្មសិទ្ធិ" ។

- Slide 8

វិធីចាត់ចែងជាបណ្ដោះអាសន្ន មានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៤៩។ ការសរសេរថា "កូនបំណុលមិនត្រូវផ្ទេរការកាន់កាប់ ឬ ផ្លាស់ប្ដូរឈ្មោះនៃការកាន់កាប់លើវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌស្ដីពីវត្ថុឲ្យទៅតតិយជនទេ" គឺបានកំណត់នូវកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ចំពោះផ្នែកដែលស្ដីពី "វត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌស្ដីពីវត្ថុ" ហើយក៏មានគោលបំណងបង្គាប់នូវសកម្មភាពជាក់លាក់ចំពោះកូនបំណុលផងដែរ ។ ការសរសេរថា "កូនបំណុលត្រូវតែលះបង់ការកាន់កាប់វត្ថុខាងលើ ហើយប្រគល់វត្ថុនេះឲ្យទៅអាជ្ញាសាលា" ជាការសរសេរ ដែលមានគោលបំណងបង្គាប់ឲ្យកូនបំណុលផ្ដល់តាវកាលិក។ ការសរសេរថា "អាជ្ញាសាលាត្រូវតែថែរក្សាគ្រប់គ្រងវត្ថុខាងលើ" ជាការសរសេរដែលមានគោលបំណងឲ្យយកកម្មវត្ថុឲ្យអ្នកថែរក្សាគ្រប់គ្រង ធ្វើការថែរក្សាគ្រប់គ្រង។ ការសរសេរផ្សេងៗក្រៅពីនេះទៀត គឺជាការសរសេរដែលបង្គាប់អំពីការចាត់ចែងដែលមានភាពចាំបាច់ផ្សេងទៀត។

ចំពោះខ្លឹមសារលម្អិត គឺយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៧១ កថា.ទី១ ដែលចែងអំពីអានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ដោយមានខ្លឹមសារថា "ដីកាសម្រេចដែលហាមឃាត់មិនឲ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុ និង បង្គាប់ឲ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឲ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឲ្យប្រគល់វត្ថុនោះ" ។

- Slide 9

ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់អំពីការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រង គឺ "អាជ្ញាសាលាមិនត្រូវអនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់វត្ថុខាងលើទេ" ហើយក្រៅពីនេះ ក៏មានទម្រង់ដូចគ្នាដែលអនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់ផងដែរ។

បើសិនជាអាជ្ញាសាលាថែរក្សាជាអ្នកគ្រប់គ្រងជាក់ស្ដែង នោះមិនចាំបាច់ប្រើពាក្យពេចន៍ជាលក្ខណៈសាធារណៈទេ ប៉ុន្តែ ចំពោះវត្ថុដែលមានតម្លៃថ្លៃដូចជាត្បូង នឹងមានភាពចាំបាច់ចំពោះស្ថានភាពនៃការថែរក្សាគ្រប់គ្រង ហើយអាជ្ញាសាលាចាំបាច់ត្រូវតែពឹងពាក់អ្នកជំនាញជាអាទិ៍ឲ្យថែក្សាគ្រប់គ្រង ហេតុនេះ ក៏ចាំបាច់នូវពាក្យពេចន៍ជាលក្ខណៈសាធារណៈដែរ។

- Slide 10

ឧទាហរណ៍អំពីខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់អំពីការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ដែលអនុញ្ញាតឲ្យម្ចាស់បំណុលប្រើប្រាស់គឺ "អាជ្ញាសាលាត្រូវតែអនុញ្ញាតឲ្យម្ចាស់

បំណុលប្រើប្រាស់វត្ថុខាងលើ" ក្រៅពីនេះគឺដូចគ្នានឹងទម្រង់ដែលអនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់ផង ដែរ "អាជ្ញាសាលាត្រូវតែអនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់វត្ថុខាងលើ"។

- Slide 12

ត្រង់ចំណុចដែលលើកឡើងថា " លើអចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុ" ជាចំណុចដែលបានកំណត់អំពីអចលនវត្ថុដែលនឹងត្រូវក្លាយជាកម្មវត្ថុនៃការហាមឃាត់ការចាត់ចែង។

- Slide 13

ខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់អំពីការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះ អាសន្ន ជាគោលការណ៍ គឺមានខ្លឹមសារដូចគ្នាទៅនឹងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬ សាលដីកា នៃរឿងអង្គសេចក្តីផងដែរ។ ប៉ុន្តែ ក្នុងករណីដែលជាការចាត់ចែងជាបណ្តោះអាសន្នដែលបានទាមទារ ឲ្យធ្វើសកម្មភាព ជាទូទៅ គឺមានភ្ជាប់នូវពាក្យថា "ជាបណ្តោះអាសន្ន" ។ ដាច់ខាតនៅដើមឃ្លាត្រូវតែ ប្រើប្រាស់ពាក្យពេចន៍ដែលមានខ្លឹមសារឲ្យផ្តល់តាវកាលិក (ដាច់ខាតមិនត្រូវប្រើពាក្យពេចន៍ដែលមាន ខ្លឹមសារថា "មានករណីយកិច្ច....." ទេ។)។

សូមអរគុណ